ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១១-៨-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៥០ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ស៊ី ស៊ូវយ៉ុង** ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅក្រុងវីសាន សាធារណរដ្ឋកូរ៉េ ៦៩២៦

២៥-៨-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៦៤ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ឡៃ តឹតឈីវ យូម៉ុក** ជនជាតិចិន សញ្ជាតិអូស្ត្រាលី កើតនៅក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ៦៩២៧

១៨-៩-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៩០៦/៣៨៣ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **ខ ភាយីន** ជនជាតិចិន សញ្ជាតិចិន កើតនៅក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ៦៩២៨

០៩-១០-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១០០៦/៤០៧ ស្តីពីការតែងតាំងលោក **ជីវ កេង** ប្រធានតុលាការក្រុងភ្នំពេញ ជាសមាជិកក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ៦៩២៩

០៩-១០-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១០០៦/៤០៨ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ ថ្នាក់ ចំពោះលោក **ឡេង សុខា** និងឯកឧត្តម **ឆេត នីថា** ៦៩៣០

០៩-១០-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១០០៦/៤០៩ ស្តីពីការតម្លើងឋានន្តរស័ក្តិ ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៣ រូប ៦៩៣១

០៩-១០-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១០០៦/៤១០ ស្តីពីការតែងតាំងឯកឧត្តម **ម៉ែន សុនសម័យ** ជាទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋមន្ត្រី ៦៩៣២

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

០៦-១០-២០០៦ -អនុក្រឹត្យលេខ ១០២ អនក្រ.បក ស្តីពីការបង្កើតការិយាល័យអនុព័ន្ធយោធា ៦៩៣៣

III_ការទារបណ្ណាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៨-៩-២០០៦ -ប្រកាសលេខ ១០១៣ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អាយ អេស អាយ ស្មៀល បង្កើតរោងចក្រ "ផលិតបំពង់ដែកទីប បំពង់អ៊ីណុក និងស័ង្កសីគ្រប់ប្រភេទ" ដែលមានឈ្មោះថា "អាយ អេស អាយ ស្មៀល" ៦៩៣៤

១៨-៩-២០០៦ -ប្រកាសលេខ ១០១៤ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អាស៊ា ម៉ូធ័រ បង្កើតរោងចក្រ "តម្លើងម៉ូតូ" ដែលមានឈ្មោះថា "អាស៊ា ម៉ូធ័រ" ៦៩៣៦

០២-១០-២០០៦ -ប្រកាសលេខ ១០៥០ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ដុង ឡុង អ៊ិនធើប្រាយ បង្កើតរោងចក្រ "ខារអំបោះ" ដែលមានឈ្មោះថា "ដុង ឡុង អ៊ិនធើ ប្រាយ" ៦៩៣៨

០៣-១០-២០០៦ -ប្រកាសលេខ ១០៦១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អេស៊ាណា និតធីង & ហ្គារមេន ហ្វេកធើរី បង្កើតរោងចក្រ "កាត់ដេរ និង ចាក់សម្លៀកបំពាក់" ដែលមានឈ្មោះថា "អេស៊ាណា និតធីង & ហ្គារមេន ហ្វេកធើរី" ៦៩៤០

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៩-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៣១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន តៃ ហ៊្វា ខូ អិលធីឌី ៦៩៤២

១០-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៥៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ចឹក សាន់ ខូ អិលធីឌី ៦៩៤៤

១០-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៥៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ឆាយម៉ុង អ៊ិនធើណេសិនណល ៦៩៤៦

១០-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៦១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន សូរីន ម៉ាឃីធីង ប្រាយវេត លីមីធីត ៦៩៤៨

១១-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៦៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស៊ីន ហេង ឈន្ធី ថេកុណឡូជី & ត្រេឌីង ៦៩៥០

១១-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៧១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផល ខ្មែរ អភិវឌ្ឍន៍ ខូ អិលធីឌី** ៦៩៥២

១១-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចាន់ ធីន គ្រុប** ៦៩៥៤

១១-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៧៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេមី ខូ អិលធីឌី** ៦៩៥៦

១១-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៧៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **នាគពីរ ខូ អិលធីឌី** ៦៩៥៨

១៤-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៨០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊ីស្តារ អេគ្រីខលឈើរ ឌីវេឡុបមេន (ខេមបូឌា) លីមីធីត** ៦៩៦០

នស/រកត/០៨០៦/៣៥០

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **សឺ ស៊ូរីយ៉ុង** (SEO SOORYONG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៤៤ នៅក្រុងវីសាន (VISAN City) សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ : [illegible]
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible]

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៦

យ៉ុន មីនកេន

នស/រកត/០៨០៦/៣៦៤

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោធិ៍ឧត្តមាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក ឡៃ ភីតធ័រ យូប៉ុក (LAI PETER YU POK) ជនជាតិចិន សញ្ជាតិអូស្ត្រាលី កើតថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៧២ នៅក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ : ៣៤៧ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

៣រស.០៧០៤.៣៥៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៦

យ៉ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៦/៣៩៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **ង កាយ៉ឹង** (NG KA YEUNG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៥៨ នៅក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ កញ្ញា ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ពរល.០៦០៩.៤០៧ លេខ: ៣៦៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៦/៤០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានតែងតាំងលោក **ជីវ កេង** ប្រធានតុលាការក្រុងភ្នំពេញ ជាសមាជិកក្រុមប្រឹក្សា**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌** ។

មាត្រា២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ តុលា ឆ្នាំ ២០០៦

ភ្ជាប់ព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣៤ល.០៦១០.៤៣១

លេខៈ ៣៨៧ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៦/៤០៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហរាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

-លោក ឡេង សុជា

-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

-ឯកឧត្តម ទេព នីថា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ពរល.០៦១០.៤៣២

លេខ : ៣៨៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៦

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

រដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី

ឈុន ជិនកេន

ព្រះរាជក្រឹត្យ

យើង

នស/រកត/១០០៦/៤០៩

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានតម្លើងឋានន្តរស័ក្តិ ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម :

ក_តម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ

-ឧត្តមសេនីយ៍ត្រី **សោម សុធា** អត្តលេខ ០០០២៤៣

ខ_តម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី

១-វរសេនីយ៍ឯក **សន ទ៊ត** អត្តលេខ ០០១៤៣១

២-វរសេនីយ៍ឯក **សៅ សារឿន** អត្តលេខ ០០១៤៦៦

មាត្រា២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែតុលាឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

លេខ : ៣៨៨ ច.ល

៣រល.០៦១០.៤៣៣

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ១០ ឆ្នាំ២០០៦

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៦/៤១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី២០ ខែមិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រមុខរដ្ឋស្តីទី

ត្រាស់បង្គាប់

មាត្រា ១: តែងតាំងឯកឧត្តម ប៉ែន សុនសម័យ ជាទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋមន្ត្រី ។

មាត្រា ២: ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៦
ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រល.០៦១០.៤៣៤

លេខ : ៣៧៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ.ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០០៦
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:....១០២....អនក្រ-បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតការិយាល័យអនុព័ន្ធយោធា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានបង្កើតការិយាល័យអនុព័ន្ធយោធាអមស្ថានទូតកម្ពុជា ប្រចាំប្រទេសអូស្ត្រាលី

មាត្រា២ : ការិយាល័យអនុព័ន្ធយោធាអមស្ថានទូតកម្ពុជាប្រចាំប្រទេសអូស្ត្រាលី ដឹកនាំដោយអនុព័ន្ធយោធាមួយរូប និងអមដោយ ជំនួយការមួយរូប ដែលត្រូវតែងតាំងដោយ រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- ឯកសារ-កាលប្បវត្តិ ✓

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១០១៣ ឧស្ស.រ៉.ថ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ១១០៨/០៦ គ.វ.ក ចុះថ្ងៃទី២១.០៣.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អាយ អេស អាយ ស្ទៀល ចុះថ្ងៃទី៣១.០៨.២០០៦

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អាយ អេស អាយ ស្ទៀល (I S I STEEL CO., LTD.) តំណាងដោយ លោក កាំង ម៉េង ហ៊ុយ សញ្ជាតិខ្មែរ អាយុ៥៨ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ 010081275 ចុះថ្ងៃទី០៣.០៨.២០០១ បង្កើតរោងចក្រ "ផលិតបំពង់ដែកទីប បំពង់អ៊ីណុក និងស័ង្កសីគ្រប់ប្រភេទ" ដែលមានឈ្មោះថា "អាយ អេស អាយ ស្ទៀល (I S I STEEL)" មានទីតាំងស្ថិតនៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និងត្រូវផ្តល់ ប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ក្នុងរយៈពេល២ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតបំពង់ដែកទីប បំពង់អ៊ីណុក និងស័ង្កសីគ្រប់ប្រភេទ" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុន ត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: ប្រកាសលេខ ១៧៤ ឧក.ប្រក ចុះថ្ងៃទី១៨.០២.១៩៩៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការបង្កើតរោងចក្រ កែច្នៃស័ង្កសី របស់ក្រុមហ៊ុន INTERNATIONAL STEEL INDUSTRIAL CO., LTD. ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១០: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន អាយ អេស អាយ ស្បៀល ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១១: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

" ដើម្បីជូនជ្រាប "

- ដូចប្រការ ១០ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ១០១៤ ឧ៩ក-កង-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ០០៨ អគវខ ចុះថ្ងៃទី៣០.០៨.២០០៦ របស់អនុគណៈកម្មាធិការវិនិយោគខេត្តកណ្តាល
- យោងពាក្យស្នើរបស់ក្រុមហ៊ុន.អាស៊ា ម៉ូធ័រ ចុះថ្ងៃទី២២.០៨.២០០៦

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អាស៊ា ម៉ូធ័រ (ASIA MOTORS CO., LTD.) តំណាងដោយលោក គង់ នួន សញ្ជាតិខ្មែរ អាយុ៤៧ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ 010338000 ចុះថ្ងៃទី០៨.០៤.២០០២ បង្កើតរោងចក្រ "តម្លើងម៉ូតូ" ដែលមានឈ្មោះថា " អាស៊ា ម៉ូធ័រ (ASIA MOTORS) " មានទីតាំងស្ថិតនៅ ភូមិត្រពាំងក្រសាំង ឃុំធក់ឈើទាង ស្រុកអង្គស្នួល ខេត្តកណ្តាល ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263.

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹងមក ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានមុន រយៈពេល១៥ថ្ងៃ និងត្រូវផ្តល់ ប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ក្នុងរយៈពេល២ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ " តម្លើងម៉ូតូ" ហើយត្រូវធ្វើរបាយការណ៍ ប្រចាំខែ អំពីស្ថានភាព ផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយដែលបានចែងខាងលើ ប្រកាសនេះ នឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និង ប្រធានក្រុមហ៊ុន អាស៊ា ម៉ូធ័រ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះ មានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-អនុគណៈកម្មាធិការវិនិយោគខេត្តកណ្តាល
" ដើម្បីជូនជ្រាប"
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១០៥០ ឧ.ស.រ.ថ.-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៨៥៥/០៦ គ.វ.ក ចុះថ្ងៃទី១២.០៩.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ដុង ឡុង អ៊ិនធើប្រាយ ចុះថ្ងៃទី០៤.០៩.២០០៦

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ដុង ឡុង អ៊ិនធើប្រាយ (DONG LONG ENTERPRISE CO., LTD.) តំណាងដោយលោក KO, CHIEN CHUNG សញ្ជាតិចិន (តៃវ៉ាន់) អាយុ៤៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 130222288 ចុះថ្ងៃទី២៦.១០.២០០០ បង្កើតរោងចក្រ "ខាអំបោះ" ដែលមានឈ្មោះថា "ដុង ឡុង អ៊ិនធើប្រាយ (DONG LONG ENTERPRISE)" មានទីតាំងស្ថិតនៅ ភូមិឬស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និងត្រូវផ្តល់ប្លង់គ្រឿងចក្រ-ម៉ាស៊ីន ក្នុងរយៈពេល ២ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "ខាអំពោះ" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ដុង ឡុង អ៊ិនធើប្រាយ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១៨៦១ ឧរ៥.ករ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែ តុលា ឆ្នាំ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៣២៧/០៦ ត.វ.ក ចុះថ្ងៃទី០១.០៩.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អេស៊ាណា នីតធីង & ហ្គាមេន ហ្វេកធើរី អិលធីឌី ចុះថ្ងៃទី២៤.០៨.២០០៦

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អេស៊ាណា នីតធីង & ហ្គាមេន ហ្វេកធើរី អិលធីឌី (ASEANA KNITTING & GARMENT FACTORY LTD.) តំណាងដោយ លោក ស៊ុម ប៊ូជីភល សញ្ជាតិ ខ្មែរ អាយុ៣៩ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ 010551594 ចុះថ្ងៃទី២៦.០៦.២០០៦ បង្កើតរោងចក្រ "កាត់ដេរ និង ចាក់សម្លៀកបំពាក់ " ដែលមានឈ្មោះថា " អេស៊ាណា នីតធីង & ហ្គាមេន ហ្វេកធើរី អិលធីឌី (ASEANA KNITTING & GARMENT FACTORY LTD.)" មានទីតាំងស្ថិតនៅ ផ្លូវលេខ ៥១ ភូមិ ញ្ញៅ ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹងមក ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និងត្រូវផ្តល់ ប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ក្នុងរយៈពេល២ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរ និងចាក់សម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីអំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុន ត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកំពង់ស្ពឺ និងប្រធានក្រុមហ៊ុន អេស៊ាណា នីតធីង & ហ្គាមេន ហ្វេកធើរី អិលធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្តកំពង់ស្ពឺ

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧០៣១ ពណ.នគក

ភ្នំពេញថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **កៃ ស៊ឺរ ខូ អិលធីឌី**
KAY SER CO., LTD
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8973/06P** ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៦
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **ឆែ នារី**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ៣៣៧ ផ្លូវព្រះមុនីវង្ស សង្កាត់អូរឬស្សីទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
